ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ...១០៥/...គជបជ
២១

# របាយការណ៍ខែឧសភា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែមិថុនា ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការបាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌ ៖**
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីបែបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការអប់រំដោយផ្ទាល់

នៅក្នុងខែឧសភា ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៨.៦៣៦**លើក មានអ្នកចូលរួមសរុបចំនួន **២៤០.៩៤០**នាក់ (ធៀបនឹងខែមេសា មានចំនួន **៤៦៤.៣៦០**នាក់ គឺមានការថយចុះចំនួន **២២៣.៤២០**នាក់ ស្មើនឹង**៤៨,១១%** ក្នុងនោះស្ត្រីចំនួន **១២៤.២៨១**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | | | | | | |
| | **សរុប ក្រសួង ស្ថាប័ន** | ០០លើក | ០០នាក់ | ០០នាក់ | ០០លើក | ០០នាក់ | ០០នាក់ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៤៣០ | ១០.២៥៧ | ៥.៣៥១ | ៤៩៦ | ៣០.១២៥ | ១៤.០៦៨ |
| ៣ | ខេត្តបាត់ដំបង | ៦៩៧ | ១៩.៦៥៩ | ១០.៨៦៩ | ៣៩៨ | ៩.៨៤៣ | ៥.២៣១ |
| ៤ | ខេត្តពោធិ៍សាត់ | ២៤៦ | ៩.៤៧៣ | ៤.៣៨៥ | ១៨ | ៥៦៦ | ២០១ |
| ៥ | ខេត្តសៀមរាប | ១១៤ | ២៣៤ | ៦៨ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.០៧៥ | ២២.០៩៤ | ១១.៨៧៨ | ៥៨៤ | ១១.១៧៣ | ៥.៥៧៩ |
| ៧ | ខេត្តកំពង់ចាម | ២.៤៣៨ | ៧៣.១១៣ | ៣៩.៤៦១ | ១.៦៧៣ | ៣៨.៨១១ | ១៩.៦៣៤ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ២ | ៣២ | ៦ | | | |
| ១០ | ខេត្តស្វាយរៀង | ២១៩ | ៧.២៦២ | ៤.២៥២ | | | |
| ១១ | ខេត្តប៉ៃលិន | ៣១ | ៤២៩ | ៨៦ | ៨ | ២០៦ | ៧៣ |
| ១២ | ខេត្តកោះកុង | | | | ៣៣ | ៧១៤ | ៣៧១ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ១១៤ | ៣.៧២២ | ១.៣៨៩ | ៣០ | ៩៦៦ | ៤២៤ |
| ១៦ | ខេត្តក្រចេះ | ១ | ២២ | ៩ | | | |
| ១៧ | ខេត្តកែប | ១៨ | ១.៧៧៨ | ៦៦៨ | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ៧ | ៣១៥ | ១៥៣ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ១៤៦ | ១២៥ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | **សរុប រាជធានី-ខេត្ត** | ៥.៣៩៦ | ១៤៨.៥៣៦ | ៧៨.៧០០ | ៣.២៤០ | ៩២.៤០៤ | ៤៥.៥៨១ |
| **សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត** | | ចំនួន ៨.៦៣៦ លើក | | ចំនួនមនុស្សសរុប ២៤០.៩៤០ នាក់ | | ចំនួនស្ត្រី ១២៤.២៨១ នាក់ | |

### ខ.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្រី |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ILO, ការីតាស់ (ខេត្តបាត់ដំបង) | ផ្សព្វផ្សាយស្តីពី ចំណាកស្រុកប្រកបដោយសុវត្ថិភាព និងឱកាសការងារក្នុងស្រុក នៅស្រុកភ្នំស្រុក និងស្រុកសំឡូត | ០២ | ៣៨ | ១៦ |
| សរុប | | ០២ លើក | ៣៨ នាក់ | ១៦ នាក់ |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| សកម្មភាព | លទ្ធផល |
|---|---|
| **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស។ | តាមវិទ្យុ **៩៩**លើក (ផ្សាយផ្ទាល់ **៣២**លើក និងចាក់ផ្សាយឡើងវិញ **៦៧**លើក) |
| **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានធ្វើការផ្សព្វផ្សាយបញ្ជ្រាប តាមវិទ្យុ FM៩៧MHz ក្នុងកម្មវិធី ព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម ចំនួន ២០ថ្ងៃក្នុង១ខែ។ | តាមវិទ្យុ **២០** លើក |
| **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយច្បាប់នានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក និងទូរទស្សន៍គោកធ្លក។ | តាមវិទ្យុ និងទូរទស្សន៍ **៥៨**លើក |
| សរុប | តាមវិទ្យុ និងទូរទស្សន៍ **១៧៧** លើក |

### ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

| សកម្មភាព | ចំនួនលើក |
|---|---|
| **ខេត្តកំពង់ចាម៖ មន្ត្រីស្នងការដ្ឋាននគរបាលខេត្ត** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ស្តីពីស្ថានភាពពលករចំណូលស្រុកនៅក្នុងមណ្ឌលចត្តាឡីស័ក | ០១លើក |
| សរុប | ០១លើក |

## ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ បានសហការជាមួយ**អង្គការ(សាម៉ារីតាន់ភឹស តំណក់ទឹក គ្រួសារថ្មី កឿនកឿន អន្តរជាតិទេសន្តរប្រវេសន៍(IOM) ក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ(CWCC) បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផ្តល់អាហារ កន្លែងស្នាក់នៅបណ្តោះអាសន្ន និងសម្ភារប្រើប្រាស់មួយចំនួន និងសេវាផ្សេងៗទៀតដូចជា ការពិនិត្យសុខភាពតេស្តរកមេរោគកូវីដ-១៩ ឱកាសការងារក្នុងប្រទេសថៃ និងការប្រឹក្សាយោបល់អំពី របៀបក្លាយខ្លួនជាពលករស្របច្បាប់ ជូនពលករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ និងម៉ាឡេស៊ី។
- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឹស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពសរុបមានចំនួន **៥៩២**នាក់(ស្ត្រី**២០៣**នាក់ កុមារា**៣៣**នាក់ កុមារី**២៨**នាក់)។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** បានបូកសរុបទិន្នន័យពលករកម្ពុជា ដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេស ក្នុងអំឡុងពេលនៃការរីករាលដាលជម្ងឺកូវីដ១៩

ប្រចាំថ្ងៃទាំង២៥ រាជធានី-ខេត្ត ដែលគិតចាប់ពីថ្ងៃទី០១ដល់៣១ ខែឧសភា ឆ្នាំ២០២១ បានចំនួន ១៣.៦១១នាក់ស្រីចំនួន៧.១០៥នាក់។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១៤២.៦១២នាក់ (ស្រី៥០.៥៩០នាក់) អនីតិជន៣១៦នាក់(ស្រី១០១នាក់)**។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ដោយខុសច្បាប់បានចំនួន **០៦**លើក មនុស្សចំនួន **៤៨**នាក់ ស្រី **១៤**នាក់ អនីតិជន**០៣**នាក់។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ដោយខុសច្បាប់បានចំនួន **០៦**លើក **មនុស្សចំនួន៦៤នាក់** ស្រី៣៣នាក់ អនីតិជន០៤នាក់។
- កម្លាំងជំនាញ នៃ**ស្នងការដ្ឋាននគរបាល**ខេត្តតាកែវចំនួន០៣លើក **មនុស្សចំនួន៣៣នាក់** ស្រី១០នាក់ សមត្ថកិច្ចបានធ្វើកិច្ចសន្យាអប់រំណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។

**ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ស្ទឹងត្រែង និងខេត្តព្រៃវែង បានល្បាត ឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ១០០លើក។

**ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **១២**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានប្រមូលព័ត៌មានពីសុខទុក្ខនារីខែដែលរៀបការ ទៅរស់នៅក្រៅប្រទេសតាមរយៈការទំនាក់ទំនងតាមទូរស័ព្ទចំនួន ០១នាក់(ប្រទេសកូរ៉េខាងត្បូង) មានសេចក្តីសុខសប្បាយជាធម្មតា។

**ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ដែលបានដាក់ចំនួន **១.២២៧**នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
- **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡដុត ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
- **ខេត្តក្រចេះ៖**
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន ០២លើក។
  - មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយអំពីខ្លឹមសារ ការកេងប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ

(ពិសេសកុមារ) តាមបណ្ដាសិប្បកម្មស្រាល នៅស្រុកព្រែកប្រសព្វ បានចំនួន០២មូលដ្ឋាន មានបុគ្គលិកចំនួន ០៨នាក់ ស្រី០២នាក់។

- **ខេត្តសៀមរាប៖**

-បានបន្តផ្សព្វផ្សាយសារ និងវីដេអូរអប់រំស្ដីអំពី **"សុវត្ថិភាពតាមអនឡាញ"** ចំនួន០៨ គ្រួសារ និង ០៨វីដេអូ តាមទំព័រហ្វេសប៊ុករបស់អង្គការសកម្មភាពដើម្បីកុមារ ដែលបានដល់ក្រុមគោលដៅដែលជាកុមារ យុវជន ឪពុកម្ដាយ អ្នកមើលថែកុមារ និងអ្នកធ្វើការជាមួយកុមារចំនួន ១,២៤៦,១៤៤នាក់ និងមានការឆ្លើយតបចំនួន ១២០,៦៣៦នាក់ សំដៅលើកទឹកចិត្តឲ្យមានការរក្សាសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។

-បានបញ្ចប់ និងផ្សព្វផ្សាយសៀវភៅជំនួយស្មារតី ស្ដីអំពីសេវាសម្រាប់ជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **៤០**ករណី(ធៀបនឹងខែមេសា មានចំនួន **៤៩**ករណី ថយចុះចំនួន **០៩**ករណី)ស្មើនឹង**១៨,៣៦%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៥៩**នាក់ (ស្រី **០៧**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន **០៤**នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **១៧៣**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ **១៧**នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុពី១៨ឆ្នាំឡើង **១៤៨**នាក់ (ប្រគល់ឱ្យគ្រួសារ **១៧៣**នាក់) ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **៣១**ករណី/៤១ករណី (ថយចុះ ១០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៥០**នាក់ (ស្រី **០៧**នាក់) អនីតិជន **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៦០**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ **០៩**នាក់ អាយុ១៥-១៧ឆ្នាំ **០៧**នាក់ និងអាយុ១៨ឆ្នាំឡើង **១៤៤**នាក់ (ប្រគល់ឱ្យគ្រួសារ **១៦០**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២៨ | ១៥៩ | ៤៦<br>អនីតិជន១ |
| -អំពើលក់ដូរមនុស្ស | ០២ | ០១ | ០២ |
| -អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន | ០១ | ០០ | ០២ |
| *សរុប* | *៣១ ករណី* | *១៦០ នាក់* | *៥០ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៩ករណី/០៨ករណី (កើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៩នាក់ អនីតិជន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៣នាក់ មាន: អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ អាយុ១៨ឆ្នាំឡើង ០៤នាក់ (ប្រគល់ឱ្យគ្រួសារ ១៣នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញាកម្មមានអនីតិជន | ០១ | ០៥ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៧ | ០៧<br>អនីតិជន៣ |
| -អំពើអាសប្រឆាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ |
| *សរុប* | *០៩ នាក់* | *១៣ នាក់* | *០៩ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ២២នាក់(ស្ត្រី ១៣នាក់ កុមារា០១នាក់ កុមារី០៥នាក់) មកពីប្រទេសចិន ១១នាក់ វៀតណាម(ឆ្លងទៅចិន) ០២នាក់ ម៉ាឡេស៊ី ០១នាក់ និងថៃ ០៨នាក់ ជាករណី(*កេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ១១នាក់ និងករណីងាយរងគ្រោះ ០៥នាក់*) បានធ្វើការសម្ភាសរួចបញ្ជូនទៅទទួលសេវានៅអង្គការដៃគូ។

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម ចំនួន ១៤លើក មនុស្សចំនួន ៣០នាក់(ស្រី ១១នាក់ អនីតិជន ០១នាក់) ក្នុងនោះមាន៖

- ខេត្តកោះកុង ចំនួន ១៣លើក មនុស្សចំនួន ២៨នាក់ (ស្រី ០៩នាក់) អនីតិជន ០១នាក់។
- ខេត្តស្វាយរៀង ចំនួន ០១លើក មនុស្សចំនួន ០២នាក់ (ស្រី ០២នាក់)។

• **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសជនទេសន្តរប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ច្រកអូរបីជាន់ និងច្រកម៉ាឡៃ ប្រចាំខែឧសភា ឆ្នាំ២០២១ មានពលករសរុបចំនួន៖ ៣.៨១៥នាក់(ស្ត្រី ១.៥៣៨នាក់) អនីតិជន ៤៤២នាក់។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

-**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)៖ ក្រុមការងារការពារជនរងគ្រោះ** និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា

សរុបចំនួន **៥៧**នាក់ (ស្ត្រី ៤១នាក់ កុមារី ១២នាក់) និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការសម្ព័ន្ធចាប់ដៃ និងសមាគមទឹកដីសន្យា។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

-**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទៅសហគមន៍វិញ សរុបចំនួន **៥២**នាក់ (ស្ត្រី៤៤នាក់ កុមារី០៨នាក់) ជាករណី( *ជួញដូរកម្លាំងពលកម្ម ០១នាក់ និងអាពាហ៍ពិពាហ៍ផ្ទុយពីធម្មនុញ្ញ/បង្ខំ ៥១នាក់*)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ក.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖

- កិច្ចប្រជុំស្តីពី៖ ១.សកម្មភាពការងារអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ ២.រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ មានអ្នកចូលរួមសរុបចំនួន **២២**រូប ស្រី **០៥**រូប។
- កិច្ចប្រជុំ រៀបចំទិសដៅឆ្នាំ២០២១របស់ គ.ជ.ប.ជ របៀបវារៈនៃអង្គប្រជុំមានចំនួន២គឺ៖ ១.ឆ្លើយតបសំណើសុំផ្តល់ធាតុចូល ក្នុងរបាយការណ៍ស្តីពី អនុសញ្ញាអន្តរជាតិ របស់អង្គការ ILO។ ២.បច្ចុប្បន្នភាពការងារ និងទិសដៅសម្រាប់ឆ្នាំ២០២១។ ជាកិច្ចបន្ត **លោកជំទាវ ជូ ប៊ុនអេង** បានផ្តល់ជាអនុសាសន៍ដល់ក្រុមការងារទាំង៦ ពិនិត្យមើលផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដើម្បីជាទុនក្នុងការឆ្លើយតប និងដាក់ផែនការបន្តក្នុងឆ្នាំ២០២១។
- កិច្ចប្រជុំ ស្តីពីសកម្មភាពការងារអាទិភាពសំខាន់ៗ និងរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។
- កិច្ចប្រជុំពិភាក្សាសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ "ស្តីពី គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ" ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា លោកប្រធានលេខាធិការដ្ឋានរដ្ឋ បាលសរុប ប្រធាន អនុប្រធានក្រុមការងារទាំង៦ និងក្រុមការងារ មន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។

- **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖**

- លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ.**ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖ ១.កិច្ចប្រជុំ ស្តីពី "ផែនការបណ្តុះបណ្តាលការកំនត់អត្តសញ្ញាណជនរងគ្រោះ"។ ២.កិច្ចប្រជុំ "រៀបចំបង្កើតតារាងទិន្នន័យជនរងគ្រោះដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់"។ ៣.កិច្ចប្រជុំ ស្តីពី "កិច្ចពិភាក្សាការងារស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសនានាអំឡុងពេលរាតត្បាតកូវីដ-១៩" តាមប្រព័ន្ធអនឡាញ ZOOM ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការអភិវឌ្ឍន៍នានា ក្នុងប្រទេសកម្ពុជា។ ៤.កិច្ចប្រជុំពិភាក្សាស្តីពី

"បែបបទ ផែនការសកម្មភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រាប់ដាក់បញ្ចូលផែនការជំរុញអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានរៀបចំកិច្ចប្រជុំចង្អៀតក្រុមការងារការពារជនរងគ្រោះ ស្តីពីកិច្ចពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសនានា អំឡុងពេលរោគរាតត្បាតកូវីដ-១៩ តាមប្រព័ន្ធអនឡាញ Zoom ដែលមាន អ្នកចូលរួមចំនួន **១៩**នាក់ ស្រី**០៧**នាក់។

### ក.២. ការទទួលជួបពិភាក្សាការងារ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ ជាមួយ៖ ១.តំណាងរបស់អង្គការវីនរ៉ក់ អំពីកិច្ចសហការរវាងកម្មវិធី Cambodia CTIP/Winrock Int'l ជាមួយនិង **គ.ជ.ប.ជ** នៅការិយាល័យរបស់លោកជំទាវផ្ទាល់។ ២.អង្គការដៃគូរអភិវឌ្ឍ និងអ្នកផ្តល់ប្រឹក្សាលើរបាយការណ៍ថ្នាក់ជាតិរបស់ គ.ជ.ប.ជ មានតំណាងពីអង្គការការីតាសកម្ពុជា អង្គការយូអិនអេហ្វភីអេ(UNFPA) អង្គការអាយជេអឹម(IJM) អង្គការCambodia-Act និងអង្គការជាដៃគូរអភិវឌ្ឍមួយចំនួនទៀត អំពីផែនការសកម្មភាពការងារ និងគម្រោងការបោះពុម្ពផ្សព្វផ្សាយរបាយការណ៍ ឯកសារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត សម្រាប់គ.ជ.ប.ជ ប្រើប្រាស់ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគម្រោងនៃការបង្កើតប្រព័ន្ធបញ្ចូលទិន្នន័យពលករ ក្នុងការគ្រប់គ្រងលំហូរពលករចេញចូល ទៅកាន់ប្រទេសគោលដៅ។

### ខ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៦៨**លើក មានអ្នកចូលរួមសរុប **៤១៥**នាក់ (ស្រី **៣២៧**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **២៨**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៩លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ០៣លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **២៨**លើក។ (**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។

- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋាន

គតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមិថុនា ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ......................ខែ..........ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី......ខែ........ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៨លើក) មនុស្សចំនួន ៤១៥នាក់ (ស្រី ៣២៧នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>-ប្រគល់ទទួល សម្ភារៈ ជាម៉ាសចំនួន៥កេស ធំ ពីតំណាងអង្គការការីតាសកម្ពុជា ជូនអគ្គលេខាធិការដ្ឋានគ ជ.ប.ជ.នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>-នាំយកនូវអំណោយ  ផ្តល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំងដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្តមានលោកស្រីអភិបាលរងខេត្ត លោកអភិបាលក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ចែកជូនពលករវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩។<br>-ចូលរួមកិច្ចប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និងគ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>-សិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការ ស្តីពីប្រធានបទ **"ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសាជាថ្មី"** តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>-ពិធីប្រគល់ទទួល សម្ភារៈ ជាម៉ាសចំនួន ៥កេសធំ ពីតំណាងអង្គការការីតាស់កម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>-កិច្ចប្រជុំស្តីពី៖ **១.**សកម្មភាពការងារជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មានអ្នកចូលរួមចំនួន **១៩**រូប ស្រី **០៣**រូប។ **២.**រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **២២**រូប ស្រី **០៥**រូប។<br>-កិច្ចប្រជុំពិភាក្សាតាមអនឡាញរវាង ASEAN-ACT និងគ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព និងផ្តោតសំខាន់ទៅលើគម្រោងរយៈពេលមួយឆ្នាំរបស់ ASEAN-ACT ក្នុងការជំរុញការអនុវត្តអនុសញ្ញា និងផែនការអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៅសាលប្រជុំគ.ជ.ប.ជ។ |

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ១-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ០៨ច្បាប់។ ២-លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៣ច្បាប់ លិខិតចូល ០៨ច្បាប់។ ៣-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ ៤-បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែឧសភា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៥-បូកសរុបរបាយការណ៍ខែឧសភា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៦-ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ ៧-រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ ៨-ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី ២០សកម្មភាព។ ៩-ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ ១០-ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន១៥១ច្បាប់។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- ឯកឧត្តម ឧត្តមសេនីយ៍ទោ ***កែវ សុវណ្ណារ៉ា*** អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ទោ **រ៉ន សុភ័ក្រ្តឡូនា** ប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការតាមប្រព័ន្ធអនឡាញ ស្តីពីប្រធានបទ **"ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសារជាថ្មី"** តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសិក្ខាកាមសរុបចំនួន **១៦៣**នាក់។
- ឯកឧត្តម ឧត្តមសេនីយ៍ទោ ***កែវ សុវណ្ណារ៉ា*** អគ្គលេខាធិការរង បានបន្តចូលរួមកិច្ចប្រជុំពិនិត្យទៅលើការអនុវត្តសកម្មភាពអទិភាពសម្រាប់អនុវត្តក្នុងត្រីមាសទី២ របាយការណ៍ វឌ្ឍនភាពការងារ និងលើកទិសដៅបន្ត ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- បានរៀបចំកសាងឯកសារស្នើសុំចុះហត្ថលេខាពី **លោកជំទាវ អគ្គលេខាធិការ គជ.ប.ជ.** ស្តីពី កិច្ចសហការពីនិយ័តករទូរគមនាគមន៍កម្ពុជា ដើម្បីបញ្ជូនការស្នើសុំរត់អក្សរសារទៅតាមបណ្តាញទូរស័ព្ទចល័តទូទាំងប្រទេសក្នុងកម្មវិធីទិវាកុមារអន្តរជាតិ១មិថុនាឆ្នាំ២០២១ ដែលមានខ្លឹមសារថា **"យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ"**។
- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី ខេត្ត និងក្រសួងស្ថាប័នពាក់ព័ន្ធ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- បានធ្វើការបូកសរុបរបាយការណ៍ខែឧសភា ឆ្នាំ២០២១ ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមកម្មវិធីប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និង គ.ជ.ប.ជ ស្តីពី៖
  - ការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

- ការបង្កើនកិច្ចសហការរវាង ស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព។
- ការចូលរួមឆ្លើយតបទៅនឹងបញ្ហាប្រឈមតាមរយៈអង្គការដៃគូរបស់កម្មវិធី ASEAN-ACT។
- ការពិភាក្សានេះ បានផ្តោតសំខាន់ទៅលើគម្រោងរយៈពេលមួយឆ្នាំ របស់ ASEAN-ACT ក្នុងការជំរុញការអនុវត្ត អនុសញ្ញា និងផែនការអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គម្រោងនេះនឹងចាប់ ផ្តើមពីខែកក្កដា ឆ្នាំ២០២១នេះតទៅ។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- **ឯកឧត្តម អគ្គលេខាធិការរង** បានទំនាក់ទំនងទៅលោកស្រី **ស៊ុន សុខាលីដា** ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោសនៃក្រសួងយុត្តិធម៌ ដើម្បីស្នើសុំបច្ចុប្បន្នភាពស្តីពី វឌ្ឍនភាពការចុះអនុសញ្ញា សន្ធិសញ្ញា បត្យាប័ន ដែលក្រសួងយុត្តិធម៌បានធ្វើជាមួយប្រទេសពាក់ព័ន្ធ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាលទ្ធផលបានទទួលហើយ។
- ចូលរួមប្រជុំដើម្បីពិភាក្សាពីលទ្ធផលការងារដែលអនុវត្តកន្លងមករយៈពេល ០៦ ឆ្នាំ) ២០១៥(២០២១- តាមវិស័យរៀងខ្លួន ឆ្លើយតបសំណើអង្គការទេសន្តរប្រវេសន៍អន្តរជាតិ តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំសម្របសម្រួល ដោយ **លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ អគ្គលេខាធិការ**។
- ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពិភាក្សាពីការជំរុញការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលក្នុងនោះមានទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១ ចំនួន០៦ចំណុចធំៗតម្រូវឱ្យក្រុមជំនួយកិច្ចការទាំង០៦ ដើម្បីពិនិត្យមើលផែនការធ្វើសកម្មភាពរបស់ខ្លួនទាំង០៤ត្រីមាសនិងលើកទិសដៅការងារក្នុង ត្រីមាសនីមួយៗច្បាស់លាស់។
- ចូលរួមប្រជុំកិច្ចការបន្ទាន់ ដើម្បីពិនិត្យទិសដៅការងារអាទិភាពសំខាន់ៗក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមការអនុវត្ត ទិសដៅការងារឆ្នាំ ២០២១ របស់ក្រសួងមហាផ្ទៃ ក្រោមការដឹកនាំ និងសម្របសម្រួលដោយ**លោកជំទាវ អគ្គលេខាធិការគជ.ប.ជ.**។
- ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ស្តីពីការជំរុញទិសដៅអនុវត្តការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលបានដាក់ចេញ០២ចំណុចមាន៖ **១.**សកម្មភាពការងារអាទិភាពសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានគជ.ប.ជ. ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ **២.**រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវរដ្ឋលេខាធិការ**ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ**។
- បានស្រាវជ្រាវ និងដកស្រង់សកម្មភាព របស់ក្រុមការងារជំនាញកិច្ចការយុត្តិធម៌អន្តរក្រសួង ចេញពីផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៣-២០១៩) ដើម្បីបង្កើតតារាងផែនការអនុសកម្មភាពឆ្នាំ២០២១ របស់ ក្រុមជំនួយកិច្ចការយុត្តិធម៌។

| | |
|---|---|
| | - បានបន្តការប្រជុំពិនិត្យមើលទិសដៅការងារជាអាទិភាព និងផែនការអនុវត្តអនុសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗដដែល។ ឆ្នាំ២០២១ នេះកំណត់ឱ្យរកតែ០៥ សកម្មភាព ឬ អនុសកម្មភាព ប៉ុណ្ណោះក្នុងមួយក្រុមដើម្បីអនុវត្ត ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** និងលោកជំទាវ **អគ្គលេខាធិការ គ.ជ.ប.ជ។**<br>- បានចូលរួមប្រជុំដើម្បីពិភាក្សាការងារជាមួយ **ឯកឧត្តម ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងឯកឧត្តម **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីត្រៀមផ្តល់ធាតុចូលក្នុងកិច្ចប្រជុំពិគ្រោះយោបល់តុមូលមួយ **«ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស»** ដែលគ្រោងនឹងធ្វើនៅពាក់កណ្តាលខែ មិថុនាខាងមុខ ទៅតាមការស្នើសុំរបស់អង្គការកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ឱ្យខាងគ.ជ.ប.ជ ជួយសម្របសម្រួល។<br>- បានទំនាក់ទំនងទៅ ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន នៃក្រសួងយុត្តិធម៌ ទទួលបន្ទុកធ្វើរបាយការណ៍ផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ដើម្បីស្នើសុំទិន្នន័យផ្តន្ទាទោសទាំង៣ដំណាក់កាល នៃនីតិវិធីតុលាការ ក្នុងត្រីមាសទី១ ឆ្នាំ២០២១។ ជាលទ្ធផលបានទទួលហើយ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំជួបសម្ភាសន៍ជាមួយមន្ត្រីជំនាញ នាយកដ្ឋានទទួលបន្ទុកអធិការកិច្ចការងារនៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនាយកដ្ឋានកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធអនឡាញ។<br>- បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំចាត់អញ្ជើញ **ឯកឧត្តម ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ដើម្បីចូលរួមកិច្ចប្រជុំសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់តុមូល ស្តីពី គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រព្រឹត្តិទៅនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដោយផ្តោតលើកិច្ចការពារកុមារ តាមវីដេអូរ Zoom។<br>- ក្រុមការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស បានទទួលជនរងគ្រោះដែលមាតុភូមិនិវត្តន៍ពីក្រៅប្រទេសនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ **០៦**លើក និងនៅច្រកព្រំដែនអន្តរជាតិបាវិត ម៉ុកបាយ **០១**លើក។<br>- ក្រុមការងារនាយកដ្ឋាន បានធ្វើសមាហរណកម្ម និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើចត្តាឡីស័កចំនួន១៤នាក់ ត្រឡប់ទៅសហគមន៍វិញ ដែលមានទីតាំងនៅ២៥រាជធានី ខេត្ត ដោយមានការចូលរួមគាំទ្រពីអង្គការដៃគូ។ |
| **អគ្គនាយកដ្ឋាន អន្តោប្រវេសន៍** | - ចាត់បញ្ជូនមន្ត្រីនគរបាល ចំនួន**០៦**រូប ចូលរួមវគ្គបណ្តុះបណ្តាល(BCAMP)លើកទី២៥ អន្តោប្រវេសន៍ឆ្ពោះទៅកាន់ឆ្នាំ២០៣០។<br>- ប្រជុំកែសម្រួលខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពី ច្បាប់អន្តោប្រវេសន៍ថ្មី នៅសាលប្រជុំអគ្គនាយកដ្ឋានអន្តោប្រវេសន៍។<br>- ប្រជុំស្តីពីសកម្មភាព វិធានការអនុវត្តក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីតំបន់បិទខ្ទប់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៨លើក អ្នកចូលរួមសរុបចំនួន ៣៦៧នាក់ (ស្រី ៣១៩នាក់)** | |

| | |
|---|---|
| **ខេត្តកណ្តាល** | - លោកជំទាវ **ហ៊ុន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានប្រជុំបូកសរុបលទ្ធការងារក្រុមការងារលេខាធិការដ្ឋានទាំង៦ ក្រុមការងារថ្នាក់ក្រុង/ស្រុកទាំង១១ ប្រចាំខែឧសភា និងលើកទិសដៅបន្ត ឆ្នាំ២០២១ របស់គ.ខ.ប.ជ ចំនួន**០១**លើក អ្នកចូលរួម **២៦**នាក់ ស្រី **២១**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ ចំនួន**០២**លើក អ្នកចូលរួម **៥៨**នាក់ ស្រី **២៨**នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន**០១**លើក អ្នកចូលរួមចំនួន**៦៥**នាក់ ស្រី**៣៤**នាក់។ |
| **ខេត្តក្រចេះ** | **មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ**<br>- បានចុះផ្សព្វផ្សាយពីរបៀបធ្វើទិវាទប់ស្កាត់ការជួញដូរមនុស្សបានចំនួន**០១**ស្រុក នៅស្រុកចិត្របុរី តាមសាលាបឋមសិក្សា១០៥ និងបឋមសិក្សាស្រះ ដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចូលរួមសរុបចំនួន **២៧**នាក់ ស្រី**១៦**នាក់។<br>- មន្ទីរបានរៀបចំឲ្យមានគណៈកម្មការទប់ស្កាត់ការជួញដូរមនុស្ស ពីថ្នាក់មន្ទីរអប់រំរហូតដល់ថ្នាក់ស្រុក និងសាលារៀន។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាខេត្ត ប្រជុំពង្រឹងសមត្ថភាពដល់មន្ត្រីយន្តការនៃ គ.ខ.ប.ជ ចំនួន**១៥**លើក អ្នកចូលរួមចំនួន**១៩១**នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លោកជំទាវប្រធានលេខាធិការដ្ឋានបានដឹកនាំកិច្ចប្រជុំក្រុមការងារ គ.ខ.ប.ជ តាមរយៈប្រព័ន្ធវិដេអូរ Zoom ចំនួន **០១**លើក។ |
| **ខេត្តកំពង់ធំ** | - ឯកឧត្តម **សុខ លូ** អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត និងឯកឧត្តម លោកជំទាវ អភិបាលរងខេត្ត រួមទាំងមន្ទីរ-អង្គភាពជុំវិញខេត្ត បានអញ្ជើញចុះសួរសុខទុក្ខពលករដែលវិលត្រឡប់មកពីធ្វើការនៅប្រទេសថៃ ដែលត្រូវដាក់ក្នុងមណ្ឌលចត្តាឡីស័កនៅតាមបណ្តាក្រុង ស្រុកទាំង៩ ក្នុងខេត្តកំពង់ធំ ដោយបានចែកសម្ភារៈ និងថវិកាមួយចំនួន។ |